# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល**
**(ខេមបូឌា) ភីអិលស៊ី**

*ថ្ងៃព្រហស្បតិ៍ ២ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់
## ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ចាប់ពីម៉ោង ០៨:០០ ព្រឹក ដល់ ១១:៣០ ថ្ងៃត្រង់ នៅទីស្នាក់ការក្រុមហ៊ុន ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ការប្រជុំតាមប្រព័ន្ធ ZOOM លោក **Chen Tsung-Chi** ជាអភិបាល និងជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន **ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី** (“**ក្រុមហ៊ុន**”) និងជាតំណាងរបស់ លោក **យ៉ាង សាវស៊ីន** ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់សិទ្ធជាប្រធានមហាសន្និបាតភាគហ៊ុនិក លើកទី៨ (“**មហាសន្និបាតភាគហ៊ុនិក**”) និងបានដឹកនាំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុននេះ។

## សមាសភាពចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក

១. គណៈអធិបតី និងភ្ញៀវកិត្តិយស និងភ្នាក់ងារបញ្ជិកា ផ្ទេរ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុន
២. ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន អាណត្តិទី២
៣. គណៈកម្មការរៀបចំដំណើរការមហាសន្និបាតភាគហ៊ុនិក លើកទី៨ និងការបោះឆ្នោត
៤. ភាគហ៊ុនិករបស់ក្រុមហ៊ុនដែលមានរាយនាមក្នុងបញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២*។

* បញ្ជីរាយនាមភាគហ៊ុនិក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ភាគហ៊ុនិកសរុប មានចំនួន ១.១២៥ នាក់។

- ចំនួនភាគហ៊ុនិកសរុប ដែលបានចុះឈ្មោះចូលរួមប្រជុំមហាសន្និបាត៖ ចំនួន ៣១ នាក់ (គិតជាភាគហ៊ុន មានចំនួន ២៩.២១១.២៩៧ ភាគហ៊ុន) ស្មើនឹង **៧៣,០៣** % នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកសរុប ដែលមានវត្តមាន នាថ្ងៃមហាសន្និបាត៖ ចំនួន ២២ នាក់ (គិតជាភាគហ៊ុន មានចំនួន ២៩.១៨៩.៦៥៦ ភាគហ៊ុន) ស្មើនឹង **៧២,៩៧%** នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។
- ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះ តែអវត្តមាន នាថ្ងៃប្រជុំមហាសន្និបាត៖ ចំនួន ៩ នាក់ (គិតជាភាគហ៊ុន មានចំនួន ២១.៦៤១ ភាគហ៊ុន) ស្មើនឹង **០,០៥%** នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

- ចំនួនភាគហ៊ុនិកសរុបដែលអវត្តមាន នាថ្ងៃមហាសន្និបាតៈ ចំនួន ១.១០៣ នាក់ (គិតជាភាគហ៊ុន មានចំនួន ១០.៨១០.៣៨៤ ភាគហ៊ុន ស្មើនឹង **២៧,០៣ %** នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

## របៀបវារៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

| | |
|---|---|
| ម៉ោង ៨:០០ - ៩:០០ | ការចុះឈ្មោះ |
| ម៉ោង ៩:០០ - ៩:១៥ | ប្រកាសហេតុ |
| ម៉ោង ៩:១៥ - ១០:០០ | បទបង្ហាញស្តីពីរបាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ ២០២១ និងឆ្នាំ២០២២ |
| ម៉ោង ១០:០០ - ១០:១៥ | សម្រាកពិសាអាហារសម្រន់ |
| ម៉ោង ១០:១៥ - ១១:៣០ | កម្មវិធីបោះឆ្នោត<br>▪ ការបោះឆ្នោតជ្រើសរើសអភិបាល និងអភិបាលឯករាជ្យថ្មី<br>▪ ការបោះឆ្នោតលើការអនុម័តបែងចែកភាគលាភជូនភាគហ៊ុនិក<br>▪ ការបោះឆ្នោតលើការអនុម័តលាភការសម្រាប់អភិបាល |
| ម៉ោង ១១:៣០ | មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ |

ការជ្រើសរើសអភិបាល និងអភិបាលឯករាជ្យថ្មីរបស់ក្រុមហ៊ុន សម្រាប់អាណត្តិ ៣ឆ្នាំ ត្រូវបានជ្រើសតាំង អនុម័ត និងសម្រេច ដោយសម្លេងបោះឆ្នោតភាគច្រើនរបស់ភាគហ៊ុនិក ដែលមានសិទ្ធបោះឆ្នោត និងមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុន ដូចខាងក្រោម ៖

- លោក **YANG PO YU** ជា អភិបាល "**ថ្មី**"
- លោកស្រី **LEE CHWEN** ជា អភិបាលឯករាជ្យ "**ថ្មី**"

ការបែងចែកភាគលាភជូនភាគហ៊ុនិក និងលាភការសម្រាប់អភិបាលរបស់ក្រុមហ៊ុន ត្រូវបានយល់ព្រម និងអនុម័ត ដោយសម្លេងបោះឆ្នោតភាគច្រើនរបស់ភាគហ៊ុនិក ដែលមានសិទ្ធបោះឆ្នោត និងមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុន ដូចខាងក្រោម ៖

ភាគលាភជាសាច់ប្រាក់ចំនួន **៦០០.០០០.០០០រៀល** ប្រមាណជា **១៥០.០០០ដុល្លារអាមេរិក** ស្មើនឹង **៥១,៣៣%** នៃប្រាក់ចំណេញក្រោយបង់ពន្ធប្រចាំឆ្នាំ២០២១ នឹងត្រូវបែងចែកជូនភាគហ៊ុនិក នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២។

១- ប្រភេទភាគលាភដែលបែងចែក : ជាសាច់ប្រាក់

២- រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០២១

៣- អនុបាតនៃការសងភាគលាភ : ៥១,៣៣% នៃប្រាក់ចំណេញក្រោយបង់ពន្ធ ប្រចាំឆ្នាំ២០២១

៤- ភាគលាភសរុបដែលបែងចែក : ៦០០.០០០.០០០ រៀល

៥- ភាគលាភក្នុងមួយឯកតាមូលបត្រមកម្មសិទ្ធ : ១៥ រៀល

៦- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភៈ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២

៧- ការបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភៈ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

លាភការ ជាសាច់ប្រាក់ចំនួន **៤០.០០០.០០០ រៀល** ប្រមាណជា **១០.០០០ដុល្លារអាមេរិក** ត្រូវប្រកាសចែកជូនក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

ក្នុងមហាសន្និបាតភាគហ៊ុនិកនេះ អង្គប្រជុំបានធ្វើបទបង្ហាញពីខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០២១ និងត្រីមាសនានា ឆ្នាំ២០២២នេះ និងកិច្ចពិភាក្សាលើបញ្ហាផ្សេងៗរបស់ក្រុមហ៊ុន រួមមាន ផែនការនៃការទិញយកភាគហ៊ុន ដោយក្រុមហ៊ុន ការផ្ទេរកម្មសិទ្ធនៃអគារ Gateway ត្រូវបានលើកយកមកពិភាក្សា អនុម័ត និងសម្រេចដោយភាគហ៊ុនិក ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុនផងដែរ។

មហាសន្និបាតភាគហ៊ុនិកនេះ បានបញ្ចប់ទៅនៅវេលាម៉ោង ១១:៣០ នាទី ព្រឹក នាថ្ងៃខែឆ្នាំ ដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**

ទីស្នាក់ការៈ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:(៨៥៥)២៣ ៨៩០ ៣២៥ /ទូរសារ :(៨៥៥)២៣ ៨៩០ ៣២៦ / គេហទំព័រ : www.Grandtwins.com.kh/ អ៊ីម៉ែល : vuthy.phuong@qmico.com